# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១_ អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩

**អនុក្រឹត្យលេខ ០៩ អនក្រ**

**ស្តីពីការបែងចែកឥណទាន**

**តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៦
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

**មាត្រា ១** : ឥណទានសំរាប់ចំណាយជាប្រចាំ និង ជាមូលធនរបស់រដ្ឋ ដែលបាន កំណត់ដោយ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ត្រូវបានបែងចែកតាមជំពូកដោយ អនុលោមទៅតាមតារាងដូចមានភ្ជាប់ នឹង អនុក្រឹត្យនេះ ។

**មាត្រា ២** : ការបែងចែកឥណទាននៃជំពូកទាំងនេះតាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌត្រូវកំ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រ ទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ តទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិង |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * *

## ការគ្រប់គ្រង ឆ្នាំ ១៩៩៧
## តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

**ឯកតា : លានរៀល**

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **០១–ព្រះបរមរាជវាំង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៥.១៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល·សំភារៈ និង ការជួសជុលតូច | ៤.៤០០ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនឥណទានប្រាក់ |
|---|---|---|
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៦.៧៦០ |
| | **សរុប ០១** | **១៦.៣០០** |
| | **០២—រដ្ឋសភា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៧.៥២៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ២.៨៦៥ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១៥០ |
| | **សរុប ០២** | **១០.៥៤០** |
| | **០៣—ទីស្តីការគណៈរដ្ឋមន្ត្រី** | |
| | **ផ្នែក ១—ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២.៦៥៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ២១.០០០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច | ២.៥០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១.៦០០ |
| | សរុប ផ្នែក ១ | ២៧.៧៥៥ |
| | **ផ្នែក ៤—រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៨០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ៣៦០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១០ |
| | សរុប ផ្នែក ៤ | ៤៥០ |
| | **ផ្នែក ៦—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៨៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ៣៦០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥ |
| | សរុបផ្នែក ៦ | ៤៥០ |
| | **ផ្នែក ៧—រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** | |

**ឯកតា : លានរៀល**

| ជំពូក | ពិរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១.៣១៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ២.៣០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥០ |
| ៥១ | ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ | ១៤.៦៧០ |
| | សរុប ផ្នែក ៧ | ១៨.៣៦៥ |
| | **សរុប ០៣** | **៤៧.០២០** |
| | **០៤—ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៦.១៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១៦.៥១០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៨៤០ |
| ៣២ | អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ | ៦.៤៥០ |
| | **សរុប ០៤** | **២៩.៩៤០** |
| | **០៥—ក្រសួងការពារជាតិ** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១៨៤.០០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុល | ៩១.៨០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥.៨០០ |
| | **សរុប ០៥** | **២៨១.៦០០** |
| | **០៦—ក្រសួងមហាផ្ទៃ** | |
| | **ផ្នែក ១—សន្តិសុខសាធារណៈ** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៤៨.៥០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុល | ៥៩.១៨៥ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១.៥០០ |
| ៥១ | ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ | ៣.៨៣០ |
| | សរុប ផ្នែក ១ | ១១៣.០១៥ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនគិតជាប្រាក់ |
|---|---|---|
| | **ផ្នែក ២—រដ្ឋបាល ទូទៅ** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៩.៩០០ |
| ១២ | ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល | ៥.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ២៥.០២០ |
| | សរុប ផ្នែក ២ | ៤០.៤៦០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៥.០៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៤.០៤០ |
| ១២ | ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល | ៩.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣២០ |
| | សរុប ផ្នែក ៩ | ១៨.៤០០ |
| | **សរុប ០៦** | **១៧១.៨៧៥** |
| | **០៧—ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | |
| | **ផ្នែក ១— ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២.១២០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៦.១៨៥ |
| ១២ | ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល | ៣.០០០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច | ១.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៨.៥៧៥ |
| | សរុប ផ្នែក ១ | ២០.៨៨០ |
| | **ផ្នែក ៩ —ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៦០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៨០០ |

**ឯកតា : លានរៀល**

| ជំពូក | បរិយាយ | ចំនួនគិតប្រាក់ |
|---|---|---|
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១៥០ |
| | សរុប ផ្នែក ៩ | ១.៥៥០ |
| | **សរុប ០៧** | **២២.៤៣០** |
| | **០៨—ក្រសួងពត៌មាន** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៨២០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៤.៧៦០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ២.៣៩៥ |
| | សរុបផ្នែក ១ | ៧.៩៩៥ |
| | **ផ្នែក ៩— ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៦០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៩៩០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥៥ |
| | សសរុបផ្នែក ៩ | ១.៦៤៥ |
| | **សរុប ០៨** | **៩.៦៤០** |
| | **០៩—ក្រសួងសាធារណការ និង ដឹកជញ្ជូន** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១.១៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៧១០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច | ២.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ៧៨.២៤៥ |
| | សរុបផ្នែក ១ | ៨២.១៣៥ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២.៩៤៥ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនគិតប្រាក់ |
|---|---|---|
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គួសជុលតូច | ១.៣៥៥ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១៥០ |
| | សរុបផ្នែក ៩ | ៤.៤៥០ |
| | **សរុប ០៩** | **៨៦.៥៨៥** |
| | **១០—ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | |
| | **ផ្នែក ១— ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣.៤០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១០.១៦០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច | ១០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២៣០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ៧៦.៩៥០ |
| | សរុបផ្នែក ១ | ៩០.៧៥០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣.៣៥០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ២.៤៧០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច | ១.៩០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១៦០ |
| | សរុប ផ្នែក ៩ | ៧.៨៨០ |
| | **សរុប ១០** | **៩៨.៦៣០** |
| | **១១—ក្រសួងយុត្តិធម៌** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣១០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១.៣០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២០ |
| | សរុបផ្នែក ១ | ១.៦៣០ |

**ឯកតា : លានរៀល**

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **ផ្នែក ២– តុលាការកំពូល** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១២៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាលសំភារៈនិងការជួសជុលតូច | ៣២០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១០ |
| | សរុបផ្នែក ២ | ៤៥៥ |
| | **ផ្នែក ៣– សាលាឧទ្ធរណ៍** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៧០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៣២០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១០ |
| | សរុបផ្នែក ២ | ៤០០ |
| | **ផ្នែក ៩– ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៧០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤៥ |
| | សរុប ផ្នែក ៩ | ១.០៨៥ |
| | **សរុប ១១** | ៣.៩៧០ |
| | **១២– ក្រសួងអប់រំយុវជន និង កីឡា** | |
| | **ផ្នែក ១– អប់រំ** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣.០៨០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១៤.៣៨០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ២៩.៨៣៥ |
| | សរុប ផ្នែក ១ | ៤៧.៥៩៥ |
| | **ផ្នែក ២– ឧត្តមសិក្សា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១.៤៤០ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនគិតប្រាក់ |
|---|---|---|
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គួសផុលតូច | ២.៩៥០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥៤០ |
| | សរុប ផ្នែក ២ | ៤.៩៣០ |
| | **ផ្នែក ៣— យុវជន និង កីឡា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣៤០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គួសផុលតូច | ១.៧៧០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៦០០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពពីបរទេសផ្ទាល់ | ៨៤០ |
| | សរុប ផ្នែក ៣ | ៣.៥៥០ |
| | **សរុប ១២** | **១២១.៣២៥** |
| | **ផ្នែក ៤ ខេត្តក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៦០.២៥០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គួសផុលតូច | ៣.៥០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១.៥០០ |
| | សរុបផ្នែក ៤ | ៦៥.២៥០ |
| | **សរុប ១២** | **១២១.៣២៥** |
| | **១៣—ក្រសួងពាណិជ្ជកម្ម** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៥៦៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គួសផុលតូច | ១.៨៥០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច | ១.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥៥ |
| | សរុប ផ្នែក ១ | ៣.៤៧០ |
| | **ផ្នែក ៤—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៥៨០ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនគិតប្រាក់ |
|---|---|---|
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៨០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៩០ |
| | សរុប ផ្នែក ៩ | ១.៤៧០ |
| | **សរុប ១៣** | **៤.៩៤០** |
| | **១៤—ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៥១៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល និង ការជួសជុលតូច | ១.៦៣០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច | ២.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ៨៤.៧១៥ |
| | សរុប ផ្នែក ១ | ៨៨.៩០០ |
| | **ផ្នែក ៩—ខេត្ត [illegible]** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៩៥០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៥០០ |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច | ៥៦៥ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៧០ |
| | សរុប ផ្នែក ៩ | ២.០៨៥ |
| | **សរុប ១៤** | **៩០.៩៨៥** |
| | **១៥—ក្រសួងផែនការ** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣១០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុល | ៨០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១៥ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានបរទេសផ្ទាល់ | ២០០ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនឥណទាន |
|---|---|---|
| | សរុប ផ្នែក ១ | ១.៣២៥ |
| | **ផ្នែក ៤—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៦០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៤០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣៥ |
| | សរុប ផ្នែក ៤ | ១.០៣៥ |
| | **១៦—ក្រសួងសុខាភិបាល** | ២.៣៦០ |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២.០៦៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៣៣.៥០០ |
| ១៣ | សកម្មភាពនៃកម្មវិធី | ២.០៤០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២០០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ៩២.៧១៥ |
| | សរុបផ្នែក ១ | ១៣០.៥២០ |
| | **ផ្នែក ៤—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៩.០០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១៣.៥០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤៤០ |
| | សរុប ផ្នែក ៤ | ២២.៩៤០ |
| | **សរុប ១៦** | **១៥៣.៤៦០** |
| | **១៧—ក្រសួងធនធានទឹក** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២៥៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ២.៦២៥ |
| ១២ | ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល | ៩៥០ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានបរទេសផ្ទាល់ | ២៥.៨៩០ |
| | សរុប ផ្នែក ១ | ២៩.៧៥០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច | ៥០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០ |
| | សរុប ផ្នែក ៩ | ៧៣០ |
| | **សរុប ១៧** | **៣០.៤៨០** |
| | **១៨—ក្រសួងធម្មការ និង សាសនា** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២៨៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច | ៥៥០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១៥ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ១៤៥ |
| | សរុប ផ្នែក ១ | ៩៩៥ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច | ៤៥០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៥០ |
| | សរុប ផ្នែក ៩ | ៨០០ |
| | **សរុប ១៨** | **១.៧៩៥** |
| | **១៩—ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១.៤១៥ |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការផ្គត់ផ្គង់តូច | ២៧.៤៦០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ២៥.២៧៥ |
| | សរុបផ្នែក ១ | ៥៤.១៨០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៤៣០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច | ៤១០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០ |
| | សរុប ផ្នែក ៩ | ៨៧០ |
| | **សរុប ១៩** | **៥៥.០៥០** |
| | **២០—ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ** | |
| | **ផ្នែក ១ – ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១.២៥០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការផ្គត់ផ្គង់តូច | ១.៨៥០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៩០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ៣.២៦០ |
| | សរុប ផ្នែក ១ | ៦.៤៥០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១.១០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច | ៧៦០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៩០ |
| | សរុបផ្នែក ៩ | ១.៩៥០ |
| | **សរុប ២០** | **៨.៤០០** |
| | **២១—ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន** | |
| | **ផ្នែក ១—ក្រសួង** | |

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ចំនួនឥណទាន |
|---|---|---|
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣៨៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ៩០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២៥៥ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ១២.៣៥៥ |
| | សរុបផ្នែក ១ | ១៣.៨៩៥ |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៨៥០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤៩.០០០ |
| | សរុប ផ្នែក ៩ | ៥០.៨៥០ |
| | **សរុប ២១** | **៦៤.៧៤៥** |
| | **២២—ក្រសួងបរិស្ថាន** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២៥០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ១.៤៥០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២០ |
| | សរុបផ្នែក ១ | ១.៧២០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣២០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៥៤០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤០ |
| | សរុប ផ្នែក ៩ | ៩០០ |
| | **សរុប ២២** | **២.៦២០** |

**ឯកតា : លានរៀល**

| ជំពូក | បរិយាយ | ចំនួនឥណទាន |
|---|---|---|
| | **២៣—ក្រសួងអភិវឌ្ឍន៍ជនបទ** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៣០០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារ និង ការជួសជុលតូច | ១.០០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ១០ |
| ៥១ | ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់ | ១១.៦៦០ |
| | សរុបផ្នែក ១ | ១២.៩៧០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ៧៧៥ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៦០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៤៥ |
| | សរុប ផ្នែក ៩ | ១.៤២០ |
| | **សរុប ២៣** | **១៤.៣៩០** |
| | **២៤—ក្រសួងកិច្ចការនារី** | |
| | **ផ្នែក ១—ក្រសួង** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ១៣០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៤៩០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ២១០ |
| | សរុប ផ្នែក ១ | ៨៣០ |
| | **ផ្នែក ៩—ខេត្ត ក្រុងនានា** | |
| ១០ | បៀវត្ស និង ប្រាក់បំណាច់ | ២៦០ |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | ៤០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ | ៣០ |

ឯកតា : លានរៀល

| ជំពូក | អធិប្បាយ | ចំនួនឥណទាន |
|---|---|---|
| | សរុប ផ្នែក ៩ | ៦៩០ |
| | សរុប ២៤ | ១.៥២០ |
| | ៩៩–ចំណាយមិនទាន់បែងចែក | |
| ២០ | ការប្រាក់នៃការខ្ចីរយៈពេលវែង មធ្យម និង ខ្លី | ២២.៦០០ |
| ៤០ | ចំណាយផ្សេងៗ | ២០០ |
| ៤១ | ចំណាយមិនបានគ្រោងទុក | ៥.០០០ |
| ៥០ | ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក | ១២២.៥០០ |
| ៥៣ | ការទូទាត់ប្រាក់ខ្ចី | ១៥.៨០០ |
| | សរុប ៩៩ | ១៦៦.៣០០ |
| | សរុបចំណាយរដ្ឋបាលកណ្តាល : | ១.១៤៤.២០០ |
| | សរុបចំណាយខេត្ត ក្រុង : | ១៨៦.០០០ |
| | សរុបចំណាយមិនទាន់បែងចែក : | ១៦៦.៣០០ |
| | សរុបរួម : | ១.៤៩៦.៥០០ |

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ ១០ អនក្រ.បក
## ស្តីពីនីតិវិធីនៃការអនុវត្តន៍
## វិន័យចំពោះមន្ត្រីរាជការស៊ីវិល

* * * *

## រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីផង

**សំរេច**

**ជំពូកទី១**

**កំហុសខាងវិន័យ**

**មាត្រា ១** :កំហុសខាងវិន័យគឺការកើតឡើងពីការប្រព្រឹត្តិ ដោយចេតនា ឬ អចេតនា ការខកខានមិនបានប្រព្រឹត្ត ការភ្លេចភ្លាំង ការធ្វេសប្រហែស ការខ្ជីខ្ជា និងរាល់ការបំពានទៅលើជំពូកទី ៥ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៣ ៣៤ ៣៥ ៣៧ ៣៨ ៣៩ ដែលកំណត់តាមឆន្ទានុសិទ្ធិនៃអាជ្ញាធរដាក់វិន័យថា ជាការខ្វះខាត ក្នុងភារកិច្ចបំពេញការងារ ។

មាត្រា ២ : រាល់កំហុសខាងវិន័យដែលប្រព្រឹត្តដោយអ្នករាជការណាម្នាក់ត្រូវអោយអ្នករាជការនោះទទួលទណ្ឌកម្មខាងវិន័យ ដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។ កំហុសខាងវិន័យកំហុសខាងរដ្ឋប្បវេណី និងកំហុសខាងព្រហ្មទណ្ឌមានភាពស្វយ័តរវាងគ្នា ។ ទណ្ឌកម្មរដ្ឋប្បវេណី ឬ ទណ្ឌកម្មព្រហ្មទណ្ឌ ក៏មានភាពស្វ័យតរវាងគ្នាដែរ ។

## ជំពូកទី២

## នីតិវិធីអនុវត្តវិន័យពាក់ព័ន្ធនឹងទណ្ឌកម្មថ្នាក់ទី ១

មាត្រា ៣ : មន្ត្រីរាជការជាប់ចោទប្រកាន់មានសិទ្ធិសុំមើលសំណុំរឿងខ្លួន តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ការសុំមើលសំណុំរឿងត្រូវធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីបានទទួលដំណឹងជាផ្លូវការ ពីប្រធានអង្គភាព ឬ ស្ថាប័នសាមី ។ អ្នកទទួលខុសសំណុំរឿងត្រូវរក្សាការសំងាត់នូវឈ្មោះសាក្សី ។ សាមីខ្លួនអាចធ្វើលិខិតតវ៉ាទៅប្រធានស្ថាប័នក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ក្រោយពីបានមើលសំណុំរឿង ។

មាត្រា ៤ : ក្រោយពីបានទទួលការពន្យល់ដោះសា ឬក្នុងករណីដែលគ្មានការដោះសាពីអ្នករាជការក្នុងរយៈពេលកំណត់ដូចខាងលើ ប្រធានស្ថាប័នអាចសំរេចយកចំណុចណាមួយដូចខាងក្រោម :

- ទុកសំណុំរឿងដោយមិនបាច់មានវិធានការបន្ត
- ធ្វើការស្តីបន្ទោស
- មានវិធានការដាក់ទណ្ឌកម្មខាងវិន័យ ថ្នាក់ទីមួយផ្សេងទៀតតាមនីតិវិធី

មាត្រា ៥ : រូបភាពវិន័យស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួនដោយប្រធានអង្គភាព ឬ ប្រធានស្ថាប័ន ។ លិខិតស្តីបន្ទោសនេះអស់ប្រសិទ្ធភាពក្រោយរយៈពេល ១ ឆ្នាំ លើកលែងតែក្នុងរយៈពេលនោះសាមីខ្លួន បានប្រព្រឹត្តខុសឆ្គងអ្វីមួយបន្ថែម ទៀត ។ រូបភាពវិន័យស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួនការ ផ្លាស់ដោយបង្ខំ និងការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

ការស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំ អាចមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ ក្នុងករណីសាមីខ្លួនមិនបានប្រព្រឹត្តខុសថ្មីទៀត ។

ចំពោះការផ្លាស់ដោយបង្ខំសាមីខ្លួនពុំមានសិទ្ធិវិលត្រឡប់មកកាន់តំណែង ដើមវិញជាស្វ័យប្រវត្តិ ។

ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិ ឬថ្នាក់ត្រូវអនុវត្តក្នុងឆ្នាំរហូតដល់ពេលធ្វើតារាងឡើងឋានន្តរសក្តិ ឬ ថ្នាក់នៃឆ្នាំបន្ទាប់ ។

ទណ្ឌកម្មនេះនឹងអស់ប្រសិទ្ធភាពលុះណាតែក្នុងរយៈពេលខាងលើ សាមីខ្លួនពុំបានប្រព្រឹត្តខុសឆ្គងអ្វីមួយបន្ថែមទៀត ហើយករណីនេះត្រូវបញ្ជាក់ច្បាស់ក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាសដាក់ទណ្ឌកម្ម ។

## ជំពូកទី៣

## នីតិវិធីអនុវត្តវិន័យពាក់ព័ន្ធនឹងទណ្ឌកម្មថ្នាក់ទី ២

មាត្រា ៦ : រូបភាពវិន័យថ្នាក់ទី ២ មាន :

ក_ស្តីបន្ទោសជាទម្ងន់បណ្តាលអោយលុបចេញពីឡើងតារាងឋានន្តរសក្តិ ឬ ថ្នាក់បើសិនជាមានចុះឈ្មោះហើយ ឬធ្វើអោយយឺតក្នុងការឡើងឋានន្តរសក្តិ ឬ ថ្នាក់ក្នុងថេរវេលាមួយមានកំណត់ តែមិនត្រូវអោយលើសពី ២ ឆ្នាំក្នុងការតំលើងឋានន្តរសក្តិ ឬ ថ្នាក់តាមវេនជ្រើសរើស ឬ តាមវេនអតីតភាព ។

ខ_ដាក់អោយនៅទំនេរគ្មានបៀវត្ស មិនអោយលើសពី ១ ឆ្នាំ ។

គ_បន្ថយឋានន្តរសក្តិ ឬថ្នាក់ ១ ថ្នាក់ ឬច្រើនថ្នាក់ ។

ឃ_ដាក់អោយចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ ។

ង_បណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ ។

ការចោទប្រកាន់អំពីកំហុសខាងវិន័យថ្នាក់ទី២ ត្រូវមានការអង្កេតជាមុនសិន ។

ការអង្កេតត្រូវប្រគល់អោយតំណាងប្រធានស្ថាប័នសាមីមួយរូប ឬច្រើនរូបដែលមានឋានន្តរសក្តិ និងថ្នាក់ខ្ពស់ជាង ឬ មានឋានន្តរសក្តិស្មើគ្នាតែមាន

អតីតភាពការងារច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទប្រកាន់ ។ ក្នុងការអង្កេតសាមីខ្លួន ត្រូវបានអញ្ជើញជាផ្លូវការមកមើលសំណុំរឿងខ្លួន និងតវ៉ាតាមលក្ខខ័ណ្ឌនិងពេលវេលាដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។ ការអង្កេតនេះមានរយៈពេល ២ ខែយ៉ាងយូរ ។

សំណុំរឿងអង្កេតរួចហើយ ត្រូវបញ្ជូនទៅប្រធានស្ថាប័ន ដើម្បីពិនិត្យនិងសំរេចថាគួរបញ្ជូនអ្នករាជការជាប់ចោទប្រកាន់នោះ អោយទៅក្រុមប្រឹក្សាវិន័យ ឬ ក៏សំរេចថា បញ្ឈប់ការចោទប្រកាន់វិញ ឬ ដាក់វិន័យត្រឹមថ្នាក់ទី ១ ។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថា គួរបន្តការចោទប្រកាន់សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យ ។

របាយការណ៍ឬការវាយតំលៃរបស់អធិការដ្ឋាន ឬអគ្គាធិការដ្ឋាន មានលក្ខណៈចាំបាច់សំរាប់ប្រធានស្ថាប័ន ក្នុងករណីដែលការចោទប្រកាន់មិនប៉ះពាល់ដល់អធិការឬអគ្គាធិការ ។

**មាត្រា ៧** : ការតែងតាំងក្រុមប្រឹក្សាវិន័យត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។ ក្រុមប្រឹក្សាវិន័យត្រូវបានបង្កើតឡើងទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលមានបញ្ហាខាងវិន័យកើតឡើង ។

**មាត្រា ៨** : ក្រុមប្រឹក្សាវិន័យត្រូវមានសមាជិក ៥ រូប :

-អ្នករាជការ ០៣ នាក់ តាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការជាប់ចោទប្រកាន់នោះ នៅក្រោមនិវាទក្នុងនោះម្នាក់បំពេញមុខងារជាប្រធាន ម្នាក់ទៀតបំពេញមុខងារជាសមាជិក រាយការណ៍និងអ្នកទី ៣ ជាសមាជិក ។

-អ្នករាជការ ០២ នាក់ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា នឹងអ្នករាជការជាប់ចោទប្រកាន់ ក៏ប៉ុន្តែមានឋានន្តរសក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។

ក្នុងករណីអគ្គនាយក ឬអគ្គាធិការត្រូវបញ្ជូនទៅក្នុងក្រុមប្រឹក្សាវិន័យ ក្រុមប្រឹក្សាវិន័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្នុងចំណោមមន្ត្រីរាជការ ដែលមានក្របខ័ណ្ឌជាមួយគ្នា មានឋានន្តរសក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ដែលធ្វើការនៅអង្គភាពផ្សេងនៃស្ថាប័នជាមួយគ្នា ។ ក្នុង

ករណីពុំមានមន្ត្រីរាជការដូចពោលខាងលើ រាជរដ្ឋាភិបាលស្នើសុំសំរេចតែងតាំងក្រុមប្រឹក្សាវិន័យ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់មកពីស្ថាប័នផ្សេងៗក៏បាន ។

មិនអាចចាត់តាំងអោយចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទប្រកាន់ ឬជាក្រុមញាតិរហូតដល់ជួរទី ៣ របស់អ្នករាជការជាប់ចោទប្រកាន់នោះ ។

**មាត្រា ៩** : ក្រោយពេលក្រុមប្រឹក្សាវិន័យត្រូវបានតែងតាំងរួចហើយ ប្រធានស្ថាប័នដែលគ្រប់គ្រងអ្នករាជការនោះ ត្រូវបញ្ជូនសំណុំរឿងទាំងអស់ពាក់ព័ន្ធនឹងអ្នករាជការជាប់ចោទប្រកាន់ទៅអោយប្រធានក្រុមប្រឹក្សាវិន័យ ដែលត្រូវបញ្ជូនទៅអោយសមាជិករាយការណ៍ ។

**មាត្រា ១០** : សមាជិករាយការណ៍ត្រូវអោយអ្នករាជការជាប់ចោទប្រកាន់ មើលសំណុំរឿងផ្ទាល់ខ្លួននិងអោយផ្តល់នូវបញ្ជីកសិណសាក្សី ព្រមទាំងឈ្មោះតំណាងការពារខ្លួន ។ បន្ទាប់មកសមាជិករាយការណ៍ត្រូវធ្វើអង្កេតស៊ើបសួររឿងនោះដោយ :

- ទាររកសំអាងផ្សេងៗ បើសិនជាការចាំបាច់ ។
- ស្រង់យកចម្លើយរបស់កសិណសាក្សីបើសិនជាមាន ។
- ស្តាប់ការពន្យល់ផ្ទាល់មាត់និងមតិតំណាងការពារដែលជាអ្នករាជការ។
- ទទួលយកពាក្យតវ៉ារបស់អ្នករាជការជាប់ចោទប្រកាន់ ។

សមាជិករាយការណ៍ ត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរពីលទ្ធផលអង្កេតដោយមិនបញ្ចេញយោបល់ផ្ទាល់ខ្លួនក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ ហើយបញ្ជូនរបាយការណ៍ជាបន្ទាន់ទៅប្រធានក្រុមប្រឹក្សាវិន័យ ។

**មាត្រា ១១** : ក្រោយពេលដែលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំយ៉ាងយូរក្នុងរយៈពេល ១៥ ថ្ងៃ ។ ក្នុងករណីសំណុំលិខិតមិនទាន់គ្រប់គ្រាន់ ប្រធានអាចបង្គាប់អោយសមាជិករាយការណ៍រកពតិមានបន្ថែមទៀត និងពន្យារពេលប្រជុំទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារៈប្រយោជន៍ ដើម្បីរកការពិតនិងកុំអោយប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យរបស់តុលាការ ក្នុងករណីដែលតុលាការបានសំរេចពីមុនមកហើយ ។

ការស្រាវជ្រាវខាងលើនេះ មិនត្រូវអោយលើសពី ២ ខែឡើយ ។

ក្នុងករណីចាំបាច់ដែលមានភាពពិបាកក្នុងការស្រាវជ្រាវពត៌មាន ប្រធានក្រុមប្រឹក្សាវិន័យអាចពន្យារពេលប្រជុំបានត្រឹមតែ ២ ខែទៀត ។

**មាត្រា ១២ :** ក្រុមប្រឹក្សាវិន័យបើកការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ដោយត្រូវតែមានវត្តមានសមាជិកគ្រប់ចំនួន ។ ក្នុងករណីដែលសមាជិកណាមួយអវត្តមាន ដោយមានធុរៈប្រធានស្ថាប័នត្រូវមានវិធានការបំពេញបន្ថែមសមាជិកថ្មីជំនួសបង្គ្រប់ ។ អ្នករាជការជាប់ចោទប្រកាន់ ត្រូវតែចូលបង្ហាញខ្លួនតាមការអញ្ជើញនោះ ។ អ្នករាជការជាប់ចោទប្រកាន់ដែលចូលបង្ហាញខ្លួនតាមការអញ្ជើញ អាចនាំតំណាងការពារខ្លួនដែលជាអ្នករាជការនិងសាក្សីមកជាមួយ ។

អ្នករាជការជាប់ចោទប្រកាន់នោះ អាចដោះសាបំភ្លឺការពារខ្លួនឯង ឬតាមរយៈតំណាងការពារខ្លួនដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ។

**មាត្រា ១៣ :** ក្រោយពីពិភាក្សាសាកសួរយកពត៌មានចប់សព្វគ្រប់ហើយ ក្រុមប្រឹក្សាវិន័យថយទៅពិគ្រោះពិចារណាសន្និដ្ឋានដោយសម្ងាត់ ។ បន្ទាប់មកក្រុមប្រឹក្សាវិន័យធ្វើការបោះឆ្នោតដោយសម្ងាត់ជាបន្តបន្ទាប់ ចាប់តាំងពីទណ្ឌកម្មខាងវិន័យកំរិតខ្ពស់បំផុតចុះមក ។ ការបើកសន្លឹកឆ្នោតត្រូវបើកទាំងអស់តែម្តងនៅពេលបោះឆ្នោតតាមកំរិតទណ្ឌកម្មនីមួយៗ រួចហើយបើមានសម្លេងស្មើគ្នាត្រូវបោះឆ្នោតលើកំរិតទណ្ឌកម្មខាងវិន័យនោះម្តងទៀត ។

**មាត្រា ១៤ :** កំណត់ហេតុលទ្ធផលនៃការពិភាក្សា និងការបោះឆ្នោតសម្ងាត់នេះប្រធាន ក្រុមប្រឹក្សាវិន័យត្រូវធ្វើភ្លាម រួចបញ្ជូនទៅប្រធានស្ថាប័នសាមី ព្រមទាំងធ្វើសេចក្តីជូនដំណឹងមួយទៀត ស្តីអំពីកំរិតទណ្ឌកម្មខាងវិន័យបញ្ជូនទៅសាមីខ្លួន អោយទទួលយកដោយមានចុះហត្ថលេខាបញ្ជាក់មកវិញផង ។ ក្នុងករណីដែលមន្ត្រីរាជការជាប់ចោទប្រកាន់ មិនព្រមទទួលសេចក្តីជូនដំណឹងនេះទេ ក្រុមប្រឹក្សាវិន័យក៏នៅតែមានសិទ្ធិបញ្ជូនសំណុំរឿងទៅប្រធានស្ថាប័នពិនិត្យ និងសំរេចដោយរាយការណ៍ជាលាយលក្ខណ៍អក្សរថា សាមីខ្លួនមិនព្រមចុះហត្ថលេខាលើសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាវិន័យទេ ។